# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធម្មការ និង សាសនា

លេខ......៣៥៧......ក.ធ.ស ៧ទ

## សេចក្តីសំរេច

## ក្រសួងធម្មការ និងសាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ០២/ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦
- បានឃើញអនុក្រឹត្យ លេខ១៣អនក្រ.បក ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងធម្មការ និងសាសនា
- ពាក្យសុំកែសំរួលរចនាសម្ព័ន្ធដឹកនាំគណៈកម្មការសង្ឃសាសនាមហាយាន ( វៀតណាម ) ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ ២០០៣
- ចំណារបញ្ជូនរបស់មន្ទីរធម្មការ និងសាសនា រាជធានីភ្នំពេញ លេខ៣៣៤ប.ជ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ ២០០៣

## ស ំ រេ ច

**ប្រការ១:** ឯកភាពលើការតែងតាំងគណៈកម្មការសង្ឃសាសនាមហាយាន ( វៀតណាម ) តាមការស្នើសុំដូចខាងក្រោម:

១-ព្រះអង្គ **ធិច ធៀងឌុង** ប្រធានគណៈកម្មការសង្ឃ ទៅជាប្រធានកិត្តិយស

២-ព្រះអង្គ **ធី អាងឡាក់** ជាប្រធានគណៈកម្មការសង្ឃ

៣- ព្រះសង្ឃ **ធិច តៀកហាន់** ជាអនុប្រធានទី១

៤-ព្រះសង្ឃ **ធិច ឆាងហ៊ុ** ជាអនុប្រធានទី២

**ប្រការ២:** គណៈកម្មការសង្ឃសាសនាមហាយាន ( វៀតណាម ) ដែលបានជ្រើសតាំងខាងលើនេះ ចាំបាច់ត្រូវធ្វើសេចក្តីរាយការណ៍ស្តីពីសកម្មភាពសាសនាមហាយាន ( វៀតណាម ) [illegible]

ក្រសួងធម្មការ និងសាសនា ដើម្បីត្រួតពិនិត្យឱ្យបានត្រឹមត្រូវនិងទៀងទាត់រៀងរាល់ ត្រីមាស ឆមាស និងឆ្នាំ ។

**ប្រការ៣:** គណៈកម្មការសង្ឃសាសនាមហាយាន ( វៀតណាម ) ត្រូវមានភារពកិច្ចគ្រប់គ្រងនិងដឹកនាំបរិស័ទ ដែលគោរពពុទ្ធសាសនា( មហាយាន ) ក្នុងន័យទ្រទ្រង់និងលើកស្ទួយសាសនានេះឱ្យបានត្រឹមត្រូវតាមពុទ្ធឱវាទរបស់ពុទ្ធសាសនា( មហាយាន) បានល្អប្រពៃ ។

**ប្រការ៤:** គណៈកម្មការសង្ឃសាសនាមហាយាន ( វៀតណាម ) ត្រូវគោរពនិងអនុវត្តឱ្យបានត្រឹមត្រូវម៉ឺងម៉ាត់តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងរាល់បទបញ្ញត្តិផ្សេងៗរបស់ក្រសួងធម្មការ និងសាសនា ។ អ្នកដឹកនាំគណៈកម្មការសង្ឃសាសនាមហាយាន ( វៀតណាម ) ត្រូវមានសាមគ្គីភាពនិងទំនាក់ទំនងឱ្យបានល្អជាមួយស្ថាប័ន-អង្គភាព ដែលពាក់ព័ន្ធ សន្យាដាច់ខាតមិនធ្វើឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពខាងជំនឿសាសនា និងសណ្តាប់ធ្នាប់របៀបរៀបរយសង្គម ។

**ប្រការ៥:** ទុកជាមោឃ សេចក្តីសំរេច លេខ ១១៣កធស ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០០០ របស់ក្រសួងធម្មការនិងសាសនា ស្តីពីឱ្យបង្កើតគណៈកម្មការសង្ឃសាសនាមហាយាន ( វៀតណាម ) ។

**ប្រការ៦:** រាល់ការអនុវត្តទាំងឡាយណា ដែលផ្ទុយពីសេចក្តីសំរេចខាងលើ ត្រូវទទួលទោសតាមច្បាប់ជាជាធរមាន ។

**ប្រការ៧:** នាយកដ្ឋានពាហិរសាសនា - នាយកដ្ឋានរដ្ឋបាល- ខុទ្ទកាល័យ-អគ្គនាយកដ្ឋានធម្មការ គ្រប់ស្ថាប័ន-អង្គភាព ដែលមានភារៈកិច្ចពាក់ព័ន្ធ ត្រូវសហការណ៍អនុវត្តនីសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធិភាពខ្ពស់ ។

**ប្រការ៨:** សេចក្តីសំរេចនេះមានអានុភាពតតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ ២០០៣

រដ្ឋមន្ត្រី

ជា-សាវឿន

**ចម្លងជូន**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ

"ដើម្បីគោរពជូនជ្រាប"

- រាជកិច្ច ដើម្បីចុះផ្សាយ
- សាលាក្រុងភ្នំពេញ
- មន្ទីរធម្មការ និងសាសនា រាជធានីភ្នំពេញ

" ដើម្បីមុខការ "

- ឯកសារ. កាលប្បវត្តិ